

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ: ១០០៣ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**
- **ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ**

**កម្មវត្ថុ** : ករណីស្តីពីរបាយការណ៍លទ្ធផលប្រជុំថ្នាក់ខេត្ត លើការងារធ្វៀលនិងបែងចែកដីជូនប្រជាពលរដ្ឋ ដែលអាស្រ័យផលក្នុងតំបន់៣ នៃខេត្តកំពង់ធំ។

**យោង** :
- លិខិតលេខ ៤៦៩ ក.ក.ជ ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ។
- ចំណារសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន ឯកឧត្តមមេត្តាជ្រាបថា : រាជរដ្ឋាភិបាលបានឯកភាពលើរបាយការណ៍លទ្ធផលប្រជុំថ្នាក់ខេត្ត លើការងារធ្វៀលនិងបែងចែកដីជូនប្រជាពលរដ្ឋដែលអាស្រ័យផលក្នុងតំបន់៣ នៃខេត្តកំពង់ធំ ដូចខាងក្រោម ÷

១- ចំពោះដីនៅ ០៤គោលដៅ ដែលមានផ្ទៃដីសរុបចំនួន **៩០៩៧ហិកតា** (ក្នុងនោះមាន ៣១៥២ហិកតា ស្ថិតនៅភូមិគោកត្របែក ឃុំស្រឡៅ ស្រុកបារាយណ៍, ៤៨៦០ហិកតា ស្ថិតនៅឃុំកំពង់គោ និងឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ និង ១៤៨៥ហិកតា ស្ថិតនៅឃុំពាមបាង ស្រុកស្ទោង) ដែលសម្តេចតេជោនាយករដ្ឋមន្ត្រីបានប្រកាសអនុញ្ញាតធ្វៀលជូនប្រជាពលរដ្ឋនៅភូមិគោកត្របែក ឃុំស្រឡៅ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ រាជរដ្ឋាភិបាលអនុញ្ញាតដើម្បីចេញជាឯកសារគតិយុត្តធ្វៀលដីចែកជូនប្រជាពលរដ្ឋ ដែលបាននិងកំពុងអាស្រ័យផលជាលក្ខណៈគ្រួសារនៅទីនោះពិតប្រាកដ ដោយក្នុងមួយគ្រួសារនឹងទទួលបានមិនលើសពី ០៥ (ប្រាំ) ហិកតា។

២- អនុញ្ញាតឱ្យអាជ្ញាធរខេត្តកំពង់ធំ សហការជាមួយនឹងមន្ទីរពាក់ព័ន្ធជុំវិញខេត្ត ជាអ្នកចេញសលាកប័ត្រព័ត៌មាន ជូនប្រជាពលរដ្ឋដែលបានទទួលដីអាស្រ័យផលជាក់ស្តែង នៅពេលដែលរាជរដ្ឋាភិបាលអនុញ្ញាតឆ្កៀលដីក្នុងតំបន់៣ ចែកជូនប្រជាពលរដ្ឋ ដោយត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមសេចក្តីជូនដំណឹងលេខ ១០៤៤ សជណ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ។

៣- ចំពោះសំណើរបស់ថ្នាក់ខេត្តលើទំហំផ្ទៃដីចំនួន ២៨៦៧៩ហិកតា និងការសុំផ្ទេរដីពីតំបន់២ទៅតំបន់១ ចំនួន ៣៩៨៧៤,៩១ហិកតាបន្ថែមទៀត រាជរដ្ឋាភិបាលអនុញ្ញាតឱ្យអាជ្ញាធរខេត្ត ស្រុក ឃុំ ដែលពាក់ព័ន្ធ សិក្សាឱ្យបានច្បាស់លាស់ពីតម្រូវការជាក់ស្តែងរបស់ប្រជាជន ដោយអនុវត្តឱ្យស្របតាមសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលលេខ ១០៤៤ សជណ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ រួចរាយការណ៍មកក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដើម្បីពិនិត្យនិងរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច។

៤- អនុញ្ញាតធ្វើប្រតិភូកម្មអំណាចដល់អាជ្ញាធរខេត្តកំពង់ធំ ដែលមានមន្ទីរជំនាញពាក់ព័ន្ធជាសេនាធិការ មានសិទ្ធិក្នុងការសម្រេចលើគម្រោងស្នើសុំស្តារ ឬ ជួសជុលទំនប់ ប្រឡាយខ្នាតតូចនិងមធ្យម សម្រាប់នាំទឹកមកស្រោចស្រពដីស្រែរបស់ប្រជាពលរដ្ឋនៅតំបន់២ និងតំបន់៣ ទៅតាមលក្ខណៈបច្ចេកទេសនិងស្ថានភាពជាក់ស្តែង។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។ ៕

ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប៊ុន ហ៊ីយ

<u>ចម្លងជូន</u> ÷
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ឯកឧត្តមមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- ឯកឧត្តមអគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលជលផល
- អាជ្ញាធរទន្លេសាប
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក
នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប៊ិន ឈិន
- ឯកសារ- កាលប្បវត្តិ